## ធនាគារក្នុងស្រុកផ្តល់ក្តីសង្ឃឹមដល់អ្នកអាចក្លាយជាសហគ្រិនមីក្រូរាប់ពាន់នាក់

***"ប្រាក់ចំនួន ៤ 000 ដុល្លាអាមេរិកដែលប្រពន្ធខ្ញុំបានខ្ចីពីធនាគាអេស៊ីលីដា មានន័យថាពេលនេះយើងមានទុនរកស៊ីដើម្បីទិញសម្ភារៈដែលយើងត្រូវការ ដើម្បីយើងអាចបំពេញបញ្ជាទិញរបស់យើងបានយ៉ាងលឿន និងអាចផលិតឧបករណ៍ច្រើនដែលយើងអាចលក់ដើម្បីរក្សាលំហូរចំណូលចូលឱ្យបានទៀងទាត់ ។"***

-- លោក លៀប រ័ត្ន សហគ្រិនមីក្រូ

**ភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៧។** លោក លៀប រ័ត្ន ឆ្លើយយ៉ាងលឿននៅពេលដែលប្រធានធនាគារពិភពលោក លោក រ៉ូប៊ើត ហ្សេអេលិក (Robert B. Zoellick) បានសួរគាត់ថាតើការខ្ចីប្រាក់ពីធនាគារអេស៊ីលីដា បានជួយឱ្យអាជីវកម្មរបស់គាត់រីកលូតលាស់ឬទេ។ "មែន" គាត់បាននិយាយយ៉ាងមានមោទនភាព ដោយចង្អុលបង្ហាញរោងជាងរបស់គាត់នៅភ្នំពេញ ដែលនៅទីនោះបុគ្គលិកទាំង ១០ នាក់របស់គាត់ធ្វើប្រដាប់បោកស្រូវ រទេះរុញ រទេះដឹក និងឧបករណ៍កសិកម្មផ្សេងៗទៀត។ "ប្រាក់ចំនួន ៤000 ដុល្លាអាមេរិកដែលប្រពន្ធខ្ញុំបានខ្ចីពីធនាគាអេស៊ីលីដា មានន័យថាពេលនេះយើងមានទុនបង្វិលដើម្បី ទិញសម្ភារៈដែលយើងត្រូវការ ដើម្បីយើងអាចបំពេញបញ្ជាទិញរបស់យើងបានយ៉ាងលឿន និងអាចផលិតឧបករណ៍ច្រើនដែលយើងអាចលក់ដើម្បីរក្សាឱ្យមានលំហូរចំណូលចូលឱ្យបានទៀងទាត់ ។"



***លៀប រ័ត្ន ជំរាបជូនពីការងាររកស៊ីរបស់លោកដល់ប្រធានធនាគារពិភពលោក លោក ហ្សេអេលិក និងប្រតិភូរាជរដ្ឋាភិបាល***

លោក លៀប រ័ត្ន ដែលពិការជើងម្ខាងកាលពីទសវត្សរ៍ដើមឆ្នាំ ១៩៨០ នៅពេលដែលគ្រាប់ធ្លាក់ចំលើរោងម៉ាស៊ីនកិនស្រូវរបស់គាត់ បានចាប់ផ្តើមរោងជាងសិប្បកម្មតូចមួយរបស់គាត់កាលពីប្រាំឆ្នាំមុន ដោយបានឯកភាពគ្នាជាមួយប្រពន្ធរបស់គាត់ គឺបងស្រី យី ឡាប ។ ជាមធ្យមក្នុងមួយខែ អាជីវកម្មតូចនេះលក់បានប្រដាប់បោកស្រូវចំនួនប្រាំ រទេះរុញចំនួនប្រាំ និងឧបករណ៍កសិកម្ម ផ្សេងៗទៀតមួយចំនួន។

"ប្តីរបស់ខ្ញុំ និងខ្ញុំគឺជាដៃគូស្មើគ្នានៅក្នុងអាជីវកម្មនេះ" បងស្រី យី ឡាប និយាយយ៉ាងមានមោទនភាព។ "យើងទាំងពីរនាក់គ្រប់គ្រងបុគ្គលិក ចរចារការលក់ជាមួយអតិថិជន និងគ្រប់គ្រងលុយកាក់ ។"

ក្នុងដំណើរទស្សនកិច្ចទៅកាន់រោងជាងផលិតកម្មដែលកំពុងរីកលូតលាស់នេះ លោក ហ្សេអេលិក បាននិយាយថាលោកសូមស្វាគមន៍ ឱកាសជួបជាមួយនឹងសហគ្រិនកម្ពុជាពីររូប។ លោកមានប្រសាសន៍ថា *"ជោគជ័យនៃឧស្សាហកម្មមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា មានលក្ខណៈគួរអោយកត់សំគាល់ បើពិនិត្យពិចារណាទៅលើបរិយាកាសអាជីវកម្មដែលកំពុងប្រឈម និង*

*ការលំបាកក្នុងការទៅដល់តំបន់ជនបទ និងតំបន់ដាច់ស្រយាល។ ខ្ញុំមានក្តីរីករាយ ដែលធនាគារធនាគារពិភពលោក អាចមានលទ្ធភាពក្នុងការជួយធនាគារអេស៊ីលេដា ពីអង្គការមិនមែនរដ្ឋាភិបាលមួយ អោយទៅជាស្ថាប័នហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណមួយ ដែលបច្ចុប្បន្នផ្តល់ទុនបង្វិលដល់ម្ចាស់អាជីវកម្មតូចៗជាច្រើន ដែលក្នុងនោះ មានច្រើនជាងពីរភាគបី ជាស្ត្រី ។ យើងសង្ឃឹមថា នឹងជួយធនាគារអេស៊ីលេដា ពង្រីកសេវាកម្មដែលជោគជ័យរបស់ខ្លួន ទៅតំបន់ ផ្សេងៗទៀតផងដែរ។"*



***លោក ហ្សេអេលិក ចាប់ដៃជាមួយម្ចាស់សិប្បកម្ម និងអតិថិជនទិញម៉ាស៊ីនបោកស្រូវ***

បងស្រី យី ឡាប គឺជាមនុស្សម្នាក់ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា នៅទីក្រុង និងជនបទចំនួន ១៨១.000 នាក់ដែលខ្ចី សន្សំ និង/ឬ ផ្ទេរប្រាក់ ជាអតិថិជនរបស់ធនាគារអេស៊ីលីដា ។ ចាប់តាំងពីឆ្នាំ ១៩៩៣ មក ធនាគារអេស៊ីលីដាបានរីកលូតលាស់ពីអង្គការក្រៅរដ្ឋាភិបាលតូចមួយទៅជាធនាគារមួយក្នុងចំណោមធនាគារពាណិជ្ជធំៗបំផុតនៃប្រទេសកម្ពុជា និងធនាគារតែមួយគត់ដែលសំដៅបម្រើសហគ្រិនក្រីក្រ។ នៅក្នុងទូទាំងប្រទេសកម្ពុជា ធនាគារអេស៊ីលីដា មានសាខាចំនួន ១៦៦ នៅតាមខេត្ត-ក្រុងទាំង ២៤ ហើយទោះបីជាពេលនេះធនាគារ គឺជាធនាគារមានអាជ្ញាប័ណ្ណពេញលេញក្តី ក៏ធនាគារអេស៊ីលីដានៅតែផ្តោតលើការផ្តល់ប្រាក់កម្ចី ជូនដល់ សិប្បករ អ្នកលក់ដូរ អ្នករកស៊ីតាមផ្សារ និងសហគ្រិនមីក្រូ និងសហគ្រិនតូចតាចផ្សេងទៀត។

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលគឺជាសាខាហិរញ្ញប្បទានផ្នែកឯកជនរបស់ក្រុមធនាគារពិភពលោក បានបំពេញតួនាទីដ៏សំខាន់មួយ រួមជាមួយនឹងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត ក្នុងការជួយធនាគារអេស៊ីលីដាឱ្យបានរីកលូតលាស់ចូលទៅដល់ប្រការដែលស្ថាប័នសេវាវិនិយោគិនមូឌី (Moody’s Investors Service) ផ្តល់ចំណាត់ថ្នាក់ជាធនាគាមួយក្នុងចំណោមធនាគារកម្ពុជា ដែលមានការគ្រប់គ្រងល្អបំផុត។

ក្នុងឆ្នាំ ១៩៩៩ IFC ដែលត្រូវបានផ្តល់ជូនតាមរយៈ កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់មេគង្គ (IFC MPDF) ដែលទទួល មូលនិធិពីពហុអ្នកផ្តល់ជំនួយ បានជួយធនាគារអេស៊ីលីដាក្នុងការឈានទៅក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុ ពាណិជ្ជដែលមានអាជ្ញាប័ណ្ណ ពេញលេញមួយ ហើយនៅក្នុងឆ្នាំ ២00៣ IFC បានដឹកនាំម្ចាស់ភាគហ៊ុនក្នុងការបង្កើន ភាគហ៊ុនដើម្បីឱ្យធនាគារអេស៊ីលីដា អាចសម្រេចជំហានចុងក្រោយក្នុងការទទួលបាននូវអាជ្ញាប័ណ្ណធនាគារ។ IFC ក៏បានផ្តល់ប្រាក់កម្ចីសរុបចំនួន ១១ លានដុល្លា អាមេរិក ជូនដល់ធនាគារអេស៊ីលីដាផងដែរ សម្រាប់ឱ្យខ្ចីបន្តជូនដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ហើយ ក្នុង ឆ្នាំ ២00៧ បានផ្តល់ជូនធនាគារនេះនូវការធានាឥណទានពាណិជ្ជកម្មមួយដែល នឹងជួយឱ្យសហគ្រាសធុនមីក្រូតូច និងមធ្យម កាន់តែច្រើន ថែមទៀតអាចចូលទៅក្នុងទីផ្សារពិភពលោក។

ក្នុងឆ្នាំ ២០០៥ ធនាគារអេស៊ីលីដាបានទទួលរង្វាន់ភាពជាអ្នកដឹកនាំខាងផ្តល់សេវាដល់អតិថិជន (Client Leadership Award) របស់ IFC ហើយក្នុងឆ្នាំ ២០០៦ ធនាគារអេស៊ីលីដាបានទទួលរង្វាន់ CGAP មួយសម្រាប់ស្នាដៃខាងតម្លាភាពហិរញ្ញវត្ថុ។

លោក រីឆាដ រ៉ែនខិន (Richard Ranken) នាយក IFC សម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលបានអមដំណើរលោកប្រធាន ហ្សោអេលិក នៅក្នុងដំណើរទស្សនារោងជាងម៉ាស៊ីនតូចកម្ពុជានោះ បានធ្វើការសរសើរខ្ពស់ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពាណិជ្ជកម្មកម្ពុជា ដែលនៅពេលនេះបម្រើអ្នកខ្ចីជិត ៦០០.០០០ នាក់នៅក្នុងទូទាំងប្រទេសកម្ពុជា (ប្រហែល ២១ ភាគរយ នៃគ្រួសារចំនួន ២,៩ លាននៅក្នុងប្រទេស)។

*"យើងខ្ញុំនៅ IFC អាចមានលទ្ធភាពរួមចំណែកដល់ជោគជ័យនេះ ដោយសារយើងផ្តល់ទាំងហិរញ្ញប្បទាន និងទាំងឱវាទអំពីការអនុវត្តប្រសើរបំផុតក្នុងពិភពលោក ដែលត្រូវបានជួយគាំទ្រដោយវត្តមានជាក់ស្តែងដ៏រឹងប៉ឹង។ យើងខ្ញុំមានមោទនភាពណាស់អំពីជោគជ័យដែលទទួលបានដោយវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ដោយសារវាបង្ហាញយ៉ាងច្បាស់ថា សូម្បីតែនៅក្នុងបរិស្ថាន អាជីវកម្មដ៏លំបាកដូចជាបរិស្ថានអាជីវកម្មកម្ពុជាក្តី ក៏អាជីវកម្មនៅតែអាចទទួលបានជោគជ័យជាមួយនឹងការអនុវត្តល្អ និងតម្លាភាពហិរញ្ញវត្ថុ។ គ្រឹះស្ថានហិរញ្ញវត្ថុប្រកបដោយជោគជ័យរបស់កម្ពុជា ផ្តល់នូវឧទាហរណ៍ដ៏ខ្លាំងក្លាមួយសម្រាប់ផ្នែកឯកជនទាំងមូល។"*

ក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ យុទ្ធសាស្ត្ររបស់ IFC នៅក្នុងប្រទេសកម្ពុជា គឺដើម្បីគាំទ្រអាជីវកម្មក្នុង ស្រុកផ្សេងៗដ៏ទូលាយ នៅក្នុងផ្នែកឯកជនដ៏ក្មេងខ្ចី។ វិនិយោគរបស់ IFC បន្ថែមលើធនាគារអេស៊ីលីដា រួមមាន រោងចក្រទឹកសណ្តែកមួយសណ្ឋាគារមួយ និងក្រុមហ៊ុនដែលគ្រប់គ្រងអាកាសយានដ្ឋាននៅតាមគោលដៅទេសចរណ៍សំខាន់ៗ ពោលគឺសៀមរាប ភ្នំពេញ និងក្រុងព្រះ សីហនុ។ លោក រ៉ែនខិន មានប្រសាសន៍ថា "*"អាជីវកម្មទាំងនេះគឺជាគម្រូល្អ ។ ដោយសារវាមានការអនុវត្តអភិបាលកិច្ចសាជីវកម្មល្អ វាកសាងធនធានមនុស្ស ហើយវារួមវិភាគទានដល់សហគមន៍មូលដ្ឋាន។"*

*ដើម្បីព័ត៌មានបន្ថែមអំពីកម្មវិធីរបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា សូមមើលវិបសាយភាសាអង់គ្លេស:*
*http://www.worldbank.org/kh*